# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

**ច្បាប់៖ ការតម្រូវឲ្យមានការពិនិត្យមើលប្រវត្តិរូបរបស់អ្នកស្ម័គ្រចិត្ត**

## គោលបំណង

បញ្ជាក់ពីតួនាទីរបស់ក្រសួងអំពីការតម្រូវឲ្យមានការពិនិត្យមើលប្រវត្តិរូបរបស់អ្នកស្ម័គ្រចិត្តដែលជា មាតាបិតា និងអ្នកដែលនៅក្នុងសហគមន៍។

## និយមន័យ

ពាក្យថា «ភ្ញៀវ» រួមបញ្ចូលអ្នកស្ម័គ្រចិត្តទាំងអស់ដែលចូលរួមក្នុង កម្មវិធីពិសេសៗ ដំណើរកំសាន្ត ឬកម្មវិធី នៅ ឬ សម្រាប់សាលា ដែលមានតែម្តង ឬម្តងម្កាល។ ភ្ញៀវទាំងនេះមិនអាចចូលរួមសកម្មភាព មើលថែ មើលខុសត្រូវ ណែនាំ ឬ ត្រួតត្រាក្មេង ដោយគ្មានការត្រួតពិនិត្យនោះទេ។

ពាក្យថា «មាតាបិតាដែលស្ម័គ្រចិត្ត » រួមបញ្ចូល មាតាតិតា/អ្នកមើលថែ សិស្សរបស់ក្រសួង ណាដែលស្ម័គ្រចិត្តជួយ ពេញម៉ោង មិនពេញម៉ោង ឬ ម្តងម្កាល ក្នុងរយៈពេលយូរ (លើសពី៦០ថ្ងៃ) នៅ ឬសម្រាប់ សាលា ប៉ុន្តែមិនមែនជា បុគ្គលិក អ្នកម៉ៅការ ឬសិស្ស របស់ក្រសួង។

ពាក្យថា «អ្នកស្ម័គ្រចិត្តដែលមិនមែនមាតាបិតា» រួមបញ្ចូល បុគ្គលណាដែលស្ម័គ្រចិត្តជួយ ពេញម៉ោង មិនពេញម៉ោង ឬ ម្តងម្កាល ក្នុងរយៈពេលយូរ (លើសពី៦០ថ្ងៃ) នៅ ឬសម្រាប់ សាលា ប៉ុន្តែមិនមែនជា បុគ្គលិក អ្នកម៉ៅការ ឬសិស្ស របស់ក្រសួង ហើយមិនមែនជា មាតាបិតា/អាណាព្យាបាល របស់សិស្សរបស់ក្រសួង។

ពាក្យថា «អ្នកស្ម័គ្រចិត្ត» សំដៅទៅលើ មាតាបិតាដែលស្ម័គ្រចិត្ត និង អ្នកស្ម័គ្រចិត្តដែលមិនមែនមាតាបិតា។

## ច្បាប់

គេមិនតម្រូវឲ្យមានការពិនិត្យមើលប្រវត្តិរូបនៃបទឧក្រិដ្ឋអ្វី របស់ភ្ញៀវនោះទេ។

មាតាបិតាដែលស្ម័គ្រចិត្ត ត្រូវមានការពិនិត្យមើលប្រវត្តិរូបពីរប្រភេទ៖

- របាយការណ៍ពីបទឧក្រិដ្ឋនៃរដ្ឋផែនស៊ីវែនញ៉ា (Pennsylvania State Criminal History Record)
- របាយការណ៍ពីការរំលោភបំពានលើកុមារ (Child Abuse Report)

  កំណត់សម្គាល់៖ ក្រសួងមិនតម្រូវឲ្យមាតាបិតាដែលស្ម័គ្រចិត្ត បង្ហាញការពិនិត្យប្រវត្តិរូបពី FBI ទេ។ ទោះជាដូច្នេះក៏ដោយ បើសិនជាលទ្ធផលនៃការពិនិត្យមើលប្រវត្តិរូបដែលគេតម្រូវឲ្យធ្វើទាំងពីរបែប បង្ហាញថាមានទោសដោយបទឧក្រិដ្ឋអ្វីមួយ គេក៏តម្រូវឲ្យមាតាបិតាដែលស្ម័គ្រចិត្ត បង្ហាញការពិនិត្យប្រវត្តិរូបពី FBI ដែរ។

អ្នកស្ម័គ្រចិត្តដែលមិនមែនជាមាតាបិតាត្រូវមានការពិនិត្យមើលប្រវត្តិរូបបី៖

- របាយការណ៍ពីបទឧក្រិដ្ឋនៃរដ្ឋផែនស៊ីវែនញ៉ា (Pennsylvania State Criminal History Record)
- របាយការណ៍ពីការរំលោភបំពានលើកុមារ (Child Abuse Report)
- ការពិនិត្យប្រវត្តិរូបពី FBI (សម្រាប់អ្នកស្ម័គ្រចិត្តថ្មីដែលមិនមែនជាមាតាបិតា ចាប់ផ្តើមមានប្រសិទ្ធិភាពនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៨)

បុគ្គលណាដែលមានទោសដោយបទឧក្រិដ្ឋធ្ងន់ធ្ងរអ្វីមួយ (ដូចបានឲ្យនិយមន័យក្នុងនីតិវិធី) ក្នុងកំឡុងពេលប្រាំឆ្នាំ បន្ទាប់ពីថ្ងៃចេញរបាយការណ៍ គេនឹងរារាំងមិនឲ្យធ្វើជាអ្នកស្ម័គ្រចិត្តទេ។

ក្នុងករណីណាដែលការពិនិត្យមើលប្រវត្តិរូបមិនឃើញធ្លាប់មានទោសអ្វីទេ នាយកសាលានៅតែមានសិទ្ធិធ្វើការសម្រេចចិត្ត ក្នុងការមិនអនុញ្ញាតឲ្យបុគ្គលនោះចូលរួមធ្វើជាអ្នកស្ម័គ្រចិត្តនៅសាលារបស់គាត់។

អ្នកដែលនឹងក្លាយជាអ្នកស្ម័គ្រចិត្តអាចធ្វើការនៅ ឬសម្រាប់សាលាមុនពេលទទួលលទ្ធផលនៃការពិនិត្យមើលប្រវត្តិរូបដែលគេតម្រូវឲ្យ ក្នុងលក្ខណៈដូចតទៅ៖

១. ពួកគេបានផ្តល់លិខិតស្នើសុំការពិនិត្យមើលប្រវត្តិរូបដែលបានធ្វើរួចមួយច្បាប់ទៅឲ្យរដ្ឋបាលរបស់ក្រសួង
២. ពួកគេនឹងស្បថ ឬបញ្ជាក់អះអាង ជាលាយលក្ខណ៍អក្សរបញ្ជាក់ថា ពួកគេមិនធ្លាប់មានទោសអ្វី ដែលអាចដកហូតសិទ្ធិរបស់ពួកគេមិនឲ្យចូលរួមធ្វើជាអ្នកស្ម័គ្រចិត្ត ហើយ
៣. ពួកគេនឹងមិនចូលរួមសកម្មភាព មើលថែ មើលខុសត្រូវ ណែនាំ ឬ ត្រួតត្រាក្មេង ដោយគ្មានការត្រួតពិនិត្យនោះទេ។

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧